**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**

# សេចក្ដីសង្ខេបព័ត៌មាន
# អំពីបច្ចុប្បន្នភាពនៃស្ថានភាពសិទ្ធិមនុស្សនិងការអនុវត្តច្បាប់នៅកម្ពុជា

*គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា* សូមជម្រាបនិងបំភ្លឺជូនសាធារណជនទាំងអស់អំពីបច្ចុប្បន្នភាពនៃស្ថានភាពសិទ្ធិមនុស្សនិងការអនុវត្តច្បាប់នៅកម្ពុជាឆ្លើយតបទៅនឹងការការរិះគន់និងរបាយការណ៍ចោទប្រកាន់ដោយលំអៀងនិងគ្មានមូលដ្ឋានរបស់ក្រុមនិងអង្គការស្ថាប័នមួយចំនួន ដូចខាងក្រោម៖

*កិច្ចសហការជាមួយយន្តការសិទ្ធិមនុស្សអន្តរជាតិ*

១. កម្ពុជាមានឆន្ទៈខ្ពស់ចំពោះការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស ដែលបានស្ដែងចេញយ៉ាងច្បាស់តាមរយៈការផ្ដល់សច្ចាប័ន និងការទទួលយកសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិចំនួន៨ ក្នុងចំណោម៩ ដែលធ្វើឱ្យប្រទេសមួយនេះក្លាយជាប្រទេសមួយលេចធ្លោនិងឈានមុខគេក្នុងតំបន់ក្នុងនាមជាភាគីសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។

២. កម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងគ្រប់យន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជាមួយនឹងស្ថាប័នសន្ធិសញ្ញាផ្សេងៗទៀត។ ឧទាហរណ៍ ចាប់តាំងពីឆ្នាំ១៩៩៣ កម្ពុជា ជាប្រទេសតែមួយគត់ក្នុងតំបន់អាស៊ានដែលបានស្វាគមន៍ ទាំងវត្តមានអ្នករាយការណ៍ពិសេស ព្រមទាំងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីត្រួតពិនិត្យស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ហើយដែលអាណត្តិអ្នករាយការណ៍ពិសេសនិងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានអនុញ្ញាតឱ្យបន្តជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន។ លើសពីនេះ កម្ពុជា ក៏មិនដែលបានបដិសេធចំពោះសំណើទស្សនកិច្ចរបស់អ្នករាយការណ៍ពិសេសណាមួយឡើយ។

៣. បន្ថែមពីលើនេះ កម្ពុជា ក៏បានចូលរួមយ៉ាងសកម្មផងដែរក្នុងយន្តការសិទ្ធិមនុស្សក្នុងតំបន់អាស៊ាន ដោយ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងនាមជាប្រធានប្ដូរវេន បានធ្វើការរៀបចំ និងដឹកនាំកិច្ចប្រជុំនានារបស់គណៈកម្មការអន្តររដ្ឋាភិបាលសិទ្ធិមនុស្សអាស៊ាន ហៅកាត់ថា អាយឆា AICHR ដោយជោគជ័យក្នុងឆ្នាំ២០២២ កន្លងទៅនេះ។

**៤- ករណីសំណុំរឿង លោក កឹម សុខា ៖** កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ សាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រមលើសំណុំរឿងព្រហ្មទណ្ឌ ដែលមានជនជាប់ចោទឈ្មោះ កឹម សុខា ដែលត្រូវជាប់ចោទពីបទ សន្ទិដ្ឋិភាពជាមួយបរទេស ឬបទឃុបឃិតត្រូវរ៉ូវគ្នាជាមួយបរទេស ប្រព្រឹត្តនៅប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីអំឡុងឆ្នាំ១៩៩៣ ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌ។

ក្រោយពីបានធ្វើសវនាការពិភាក្សាដេញដោលចំនួន៦៦លើក ចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២ ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រម ដោយបានសម្រេចសេចក្តីដូចខាងក្រោម៖

**១.** ផ្តន្ទាទោសជនជាប់ចោទ ឈ្មោះ កឹម សុខា ដាក់ពន្ធនាគារកំណត់រយៈពេល ២៧ (ម្ភៃប្រាំពីរ) ឆ្នាំ ពីបទសន្ទិដ្ឋិភាពជាមួយបរទេស ឬបទឃុបឃិតត្រូវរ៉ូវគ្នាជាមួយបរទេស ប្រព្រឹត្តនៅប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីអំឡុងឆ្នាំ២០១០ ដល់ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៧ ជាបទល្មើសព្រហ្មទណ្ឌ និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៣៩ និងមាត្រា ៤៤៣ នៃក្រមព្រហ្មទណ្ឌ។

**២.**ផ្តន្ទាទោសជនជាប់ចោទនូវទោសបន្ថែម ដោយដកជាស្ថាពរនូវ សិទ្ធិបោះឆ្នោត សិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត និងសិទ្ធិធ្វើសកម្មភាពនយោបាយផ្សេងទៀត តាមបញ្ញត្តិមាត្រា ៤៥០ នៃក្រមព្រហ្មទណ្ឌ។

**៣.**ដាក់ជនជាប់ចោទឱ្យស្ថិតនៅក្រោមវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយត្រូវគោរពកាតព្វកិច្ចមួយចំនួនដូចខាងក្រោម ៖

-មិនត្រូវចាកចេញពីបរិវេណនៃលំនៅឋាន លើកលែងតែមានការអនុញ្ញាតដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-មិនត្រូវជួបបុគ្គលណាម្នាក់ ទាំងសញ្ជាតិខ្មែរ និងបរទេស ដោយផ្ទាល់ ឬដោយប្រយោលតាមប្រព័ន្ធបច្ចេកវិទ្យា ក្រៅពីសមាជិកគ្រួសារ លើកលែងតែមានការអនុញ្ញាតដោយព្រះ

រាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយយោងលើតម្រូវការចាំបាច់តែប៉ុណ្ណោះ។

កាតព្វកិច្ចនៃវិធានការត្រួតពិនិត្យតាមផ្លូវតុលាការខាងលើនេះ មានអានុភាពអនុវត្តភ្លាម ចាប់ពីថ្ងៃប្រកាសសាលក្រមនេះរហូតដល់ពេលសាលក្រមចូលជាស្ថាពរ។

៤.បង្គាប់ឱ្យកងកម្លាំងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រើប្រាស់សិទ្ធិអំណាច និងតួនាទីរបស់ខ្លួន ក្នុងឋានៈជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីជានាអនុវត្តនូវវិធានការត្រួតពិនិត្យតាមផ្លូវតុលាការដូចកំណត់ក្នុងចំណុចទី៣ នៃសេចក្តីសម្រេចខាងលើនេះ ក្រោមការដឹកនាំ និងសម្របសម្រួលដោយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

៥.ក្នុងករណីដែលមានការបំពាននូវកាតព្វកិច្ចនៃវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវស្នើសុំជាបន្ទាន់ទៅតុលាការមានសមត្ថកិច្ចឱ្យចេញនូវវិធានការឃុំខ្លួនជាបណ្តោះអាសន្នលើជនជាប់ចោទ។

**ចំណុចសំខាន់ៗដែលជាមូលដ្ឋានក្នុងសាលក្រម មានដូចតទៅ៖**

**ទី១-** ការជំរុញ និងការលើកកម្ពស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ មិនមែនជាអំពើខុសច្បាប់នោះឡើយ ហើយសកម្មភាពនេះត្រូវបានធានាការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែ តុលាការបានរកឃើញថា ការជំរុញ និងការលើកកម្ពស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យដែលធ្វើឡើងដោយមានការជួយជ្រោមជ្រែង ឃុបឃិតត្រូវរ៉ូវគ្នាក្នុងផែនការសម្ងាត់ជាមួយរដ្ឋបរទេស ឬភ្នាក់ងារបរទេស ក្នុងគោលបំណងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ ដោយប្រើប្រាស់កម្លាំងមហាជន ឬធ្វើបដិវត្តន៍ពណ៌ផ្តួលរំលំ ដូចនៅរដ្ឋ "ខ" និងរដ្ឋ "គ" គឺជាអំពើខុសច្បាប់ ដែលអំពើនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ សន្តិភាព សន្តិសុខជាតិ ស្ថិរភាពសង្គម និងភាពសុខសាន្តរបស់ប្រជាពលរដ្ឋទាំងមូល។ ក្នុងន័យនេះ ជនជាប់ចោទ បានប្រើប្រាស់ការលើកកម្ពស់សិទ្ធិមនុស្ស និង លទ្ធិប្រជាធិបតេយ្យ មកធ្វើជាលេស ឬជាឈ្នាន់ក្នុងការប្រមូលកម្លាំងមហាជន តាមគ្រប់មធ្យោបាយដោយស្របច្បាប់ និងមិនស្របច្បាប់ សំដៅធ្វើបដិវត្តន៍ពណ៌ ផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់ ក្រោមការឃុបឃិតត្រូវរ៉ូវគ្នាដោយសម្ងាត់ជាមួយរដ្ឋបរទេស ឬ ភ្នាក់ងារបរទេស។

**ទី២-** តាមសំណើរបស់មេធាវីរាជរដ្ឋាភិបាលតំណាងដើមបណ្តឹងរដ្ឋប្បវេណី តុលាការពុំមានសរសេរឈ្មោះរដ្ឋបរទេស ឬភ្នាក់ងារបរទេសនៅក្នុងសាលក្រមរបស់ខ្លួនឡើយ។ តុលាការសម្រេចប្រើប្រាស់អក្សរតាងចំពោះរដ្ឋបរទេស ឬភ្នាក់ងារបរទេស តាមសំណើរបស់មេធាវីរាជរដ្ឋាភិបាលតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធានាឱ្យបាននូវទំនាក់ទំនងល្អ និងផលប្រយោជន៍ជាតិនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិជាមួយរដ្ឋបរទេស។ ជាមួយនេះដែរ ដើម្បីធានាឱ្យបាននូវទំនាក់ទំនងល្អ និងផលប្រយោជន៍ជាតិនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិ និងដោយចៀសវាងឱ្យបាននូវការធ្លាយចេញនូវឯកសារជាតារាងអក្សរតាងជំនួសការហៅឈ្មោះរដ្ឋបរទេស តុលាការកំណត់ និងដាក់ឯកសារនេះ ជាឯកសារសម្ងាត់ដែលមិនត្រូវទម្លាយជាសាធារណៈនោះឡើយ។ ដូច្នេះ ផ្អែកលើមូលដ្ឋាននេះ ជនណា ឬភាគីណាមួយដែលធ្វើឱ្យធ្លាយចេញឯកសារនេះជាសាធារណៈ គឺត្រូវមានទោស ដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**ទី៣-** តុលាការបានសម្រេច មិនឃុំខ្លួនជនជាប់ចោទ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលតំណាងអយ្យការបានស្នើសុំ ប៉ុន្តែដើម្បីធានារក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីច្បាប់តុលាការបានសម្រេចដាក់ចេញនូវវិធានការចំបាច់មួយចំនួន ជំនួសអោយការឃុំខ្លួនដែលមានដូចជា៖ ១-មិនត្រូវចាកចេញពីបរិវេណនៃលំនៅឋានផ្ទះរបស់ខ្លួន លើកលែងតែមានការអនុញ្ញាតពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និង២-មិនត្រូវជួបបុគ្គលណាម្នាក់ ទាំងសញ្ជាតិខ្មែរ និងបរទេសដោយផ្ទាល់ ឬដោយប្រយោលតាមប្រព័ន្ធបច្ចេកវិទ្យា ក្រៅពីសមាជិកគ្រួសារ លើកលែងតែមានការអនុញ្ញាតពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដោយយោងលើតម្រូវការចាំបាច់តែប៉ុណ្ណោះ ។

**៥. សន្តិភាពជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សនិងការអភិវឌ្ឍ៖** នៅក្នុងឆ្នាំ២០២២ ដែលទើបតែកន្លងផុតទៅនេះ កម្ពុជាបានសម្រេចសមិទ្ធិផលថ្មីៗលើមាគ៌ានៃការអភិវឌ្ឍរបស់ខ្លួន ទោះបីជំងឺកូវីដ-១៩ មិនទាន់បានត្រូវលប់បំបាត់ទាំងស្រុង និងទទួលរងឥទ្ធិពលនៃការវិវត្តដ៏ស្មុគស្មាញនៃសភាពការណ៍អន្តរជាតិក្តី។ សន្តិភាព ស្ថេរភាពនយោបាយ និងសន្តិសុខ ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ សិទ្ធិមនុស្ស និងការរស់នៅដ៏សុខដុមរមនារបស់ប្រជាជន ត្រូវបានការពារយ៉ាងគត់មត់ដោយកម្លាំងជាតិទាំងមូល ដែលបានរួមសាមគ្គីយ៉ាងរឹងមាំជុំវិញរាជរដ្ឋាភិបាល។ ពាក្យស្លោក "**អរគុណសន្តិភាព អរគុណនយោបាយឈ្នះឈ្នះ**" បានលាន់រន្ទឺពាសពេញប្រទេស

និងបានក្លាយជាស្មារតីសង្គមជាតិដ៏ខ្លាំងក្លារស់រវើក នៅក្នុងដំណើរកសាងនិងការពារមាតុភូមិ។ បើយើងរក្សាសន្តិភាពមិនបាន យើងពិតជាមិនអាចទទួលសមិទ្ធផលគ្រប់យ៉ាងនៅថ្ងៃនេះបានឡើយ។

កម្ពុជាកំពុងឈានទៅមុខឥតឈប់ឈរតាមទិសដៅដ៏ត្រឹមត្រូវ ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន។ កម្ពុជាបានប្រែក្លាយពីវាលពិឃាតនៃរបបប្រល័យពូជសាសន៍, ពីសមរភូមិសង្គ្រាមដ៏រ៉ាំរ៉ៃ, ពីការបែកបាក់ជាតិ និងការបែងចែកទឹកដី និងពីទឹកដីមួយដែលមានខឿនសេដ្ឋកិច្ចជាតិត្រូវបំផ្លាញខ្ទិចខ្ទី ទៅជាទឹកដីដែលមានសន្តិភាព សាមគ្គីភាព ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងការអភិវឌ្ឍលើគ្រប់វិស័យ ។

**៦. ដំណើរការប្រជាធិបតេយ្យសេរីពហុបក្ស៖** កម្ពុជា ប្រកាន់ភ្ជាប់និងគោរពតាមគោលការណ៍នៃ លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ កម្ពុជា បានរៀបចំការបោះឆ្នោតជាតិ និងឃុំ-សង្កាត់ជាច្រើនអាណត្តិ មកហើយ តាមមធ្យោបាយផ្ទាល់ខ្លួន ជាមួយនឹងការចូលរួមប្រកបដោយភាពសេរី យុត្តិធម៌ និងគ្មានអំពើហិង្សា។ ជាឧទាហរណ៍ ក្នុងការបោះឆ្នោតកាលពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ កន្លងទៅនេះ គឺប្រព្រឹត្តទៅជាប្រក្រតី ដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងជាទៀតទាត់ ហើយមាន គណបក្សនយោបាយចំនួន២០ បានចូលរួមប្រកួតប្រជែង ហើយប្រជាពលរដ្ឋក៏មានសិទ្ធិសេរីភាពពេញលេញ ក្នុងការបោះឆ្នោតផងដែរ។

បច្ចុប្បន្នមានគណបក្សនយោបាយចំនួន ៤៧ បានចុះបញ្ជីរួចហើយ ហើយដំណើរការប្រជាធិបតេយ្យកំពុងបន្តទៅមុខតាមកន្លងនីតិរដ្ឋ ជាពិសេសការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី៥ បានប្រព្រឹត្តទៅដោយជោគជ័យ ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ជាមួយគ្នានេះ គ្រប់កិច្ចការនិងសកម្មភាពរបស់គណបក្សនយោបាយនានាក្នុងដំណើរឆ្ពោះទៅការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី៧ ក៏កំពុងប្រព្រឹត្តទៅយ៉ាងល្អប្រសើរ។ ទន្ទឹមនឹងនេះ កិត្យានុភាពកម្ពុជាកាន់តែបានលើកកម្ពស់ឡើងលើឆាកអន្តរជាតិ ពិសេសឆ្លងតាមជោគជ័យដ៏ត្រចះត្រចង់នៃកិច្ចប្រជុំកំពុលអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធនានាដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ក្នុងឋានៈជាប្រធានប្តូរវេនរបស់អាស៊ាន នៅរាជធានីភ្នំពេញ។

**៧. ការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ៖** ដោយមានការឯកភាពពីសម្តេចតេជោនាយករដ្ឋមន្ត្រី ប្រគល់ការងារនេះមកឱ្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ធ្វើការដឹកនាំនិងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ពេលនេះ ក្រុមការងារគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានបញ្ចប់សេចក្តីព្រាងដំបូងរបស់ខ្លួនរួចហើយ ដោយផ្អែកលើគោលការណ៍ទីក្រុងប៉ារីស និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ ដើម្បីជានាបាននូវតម្លាភាព នៃដំណើរការនៃការតាក់តែងសេចក្តីព្រាងច្បាប់នេះ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានធ្វើលិខិតអញ្ជើញជាផ្លូវការទៅការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

OHCHR ដើម្បីចូលរួមសហការ និងធ្វើជាសហប្រធានដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់និងសម្របសម្រួល អញ្ជើញភាគីខាងសង្គមស៊ីវិលឱ្យចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ។ តែផ្ទុយទៅវិញ ភាគីខាងសង្គមស៊ីវិលមួយចំនួនតូចបានបដិសេធទៅនឹងការអញ្ជើញរបស់ការិយាល័យឧត្តមស្នងការ OHCHR និងបានធ្វើការរិះគន់មកលើរដ្ឋាភិបាល ដែលនេះ បង្ហាញឱ្យឃើញច្បាស់ពីចរិត និងរបៀបវារៈនយោបាយ និងភាពគ្មានការទទួលខុសត្រូវរបស់សង្គមស៊ីវិល ទាំងអស់នេះ។

តែទោះជាយ៉ាងនេះក៏ដោយ ក៏គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នៅតែបន្តកិច្ចសហការជាមួយការិយាល័យឧត្តមស្នងការ OHCHR ក្នុងកិច្ចដំណើការពិគ្រោះយោបល់នេះតទៅទៀត ដោយបានរៀបចំនូវសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ តាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ លើសេចក្តីព្រាងច្បាប់នេះ ដោយមានការចូលរួមពីអ្នកជំនាញការជាតិ និងអន្តរជាតិ ស្ថាប័នសិទ្ធិមនុស្សអន្តរជាតិ រួមទាំងគណៈកម្មការអន្តររដ្ឋាភិបាលសិទ្ធិមនុស្សអាស៊ាន ផងដែរ ហៅកាត់ថា អាយឆា AICHR, ក្រសួងស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិ ស្ថាប័នវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងគណៈកម្មការសិទ្ធិមនុស្សនៃស្ថាប័ននីតិបញ្ញត្តិទាំងពីរថ្នាក់ ដែលមានចំនួនសរុបជាង៤០លើក។ បន្ថែមពីលើនេះ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក៏បានអនុញ្ញាតឱ្យសាធារណជនចូលរួមផ្តល់យោបល់ផងដែរលើសេចក្តីព្រាងច្បាប់នេះ តាមរយៈបណ្តាញ Channel Telegram របស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ មលដល់ពេលនេះ ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ដំបូងស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិនេះ ត្រូវបានបញ្ចប់ និងរងចាំនីតិវិធីបន្តទៅកាន់ទីស្តីការគណៈរដ្ឋមន្ត្រី។

**៨. សេរីភាពនៃការបង្កើតសមាគម និងអង្គការក្រៅរដ្ឋាភិបាល៖** . កម្ពុជាមានអង្គការក្រៅរដ្ឋាភិបាលចំនួនជាង៦០០០ ហើយរដ្ឋាភិបាលនៅតែប្តេជ្ញាចិត្តក្នុងការដោះស្រាយ បញ្ហាប្រឈមរបស់ពួកគេ តាមរយៈវេទិកាភាពជាដៃគូជាទៀងទាត់ ដែលបានបង្កើតរួចហើយ។ រដ្ឋាភិបាលក៏កំពុងពិនិត្យនិងសិក្សានីត្យានុកូលភាពនៃសំណើសុំធ្វើវិសោធនកម្មលើមាត្រាទាំង១៤ នៃច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ផងដែរ។

គ្រប់អង្គការសង្គមស៊ីវិលទាំងអស់ទាំងជាតិនិងអន្តរជាតិ ដែលធ្វើសកម្មភាពនៅកម្ពុជា ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវអធិបតេយ្យភាពនិងបញ្ញត្តិច្បាប់ជាតិរបស់កម្ពុជាដែលមានជាធរមានជាពិសេសច្បាប់ស្តីពីសមាគមនិងអង្គការក្រៅរដ្ឋាភិបាល ហើយក្នុងករណីដែលមានមូលដ្ឋានច្បាស់លាស់បញ្ជាក់ពីសកម្មភាពមិនប្រក្រតីដែលជាការបំពានច្បាប់ នោះសមត្ថកិច្ចមានសិទ្ធិធ្វើការត្រួតពិនិត្យបានគ្រប់ពេល ដើម្បីធានាបាននូវការអនុវត្តច្បាប់មួយដែលមានប្រសិទ្ធភាព នៅក្នុងសង្គមប្រជាធិបតេយ្យនីតិរដ្ឋ។

**៩. សិទ្ធិទទួលព័ត៌មាន៖** ត្រូវបានធានានិងការពារនៅកម្ពុជាតាមរយៈយន្តការច្បាប់ និងស្ថាប័ន រួមមានការរៀបចំក្របខណ្ឌច្បាប់សំខាន់ៗនិងចាំបាច់មួយចំនួនពាក់ព័ន្ធសេរីភាពសារព័ត៌មាន ជាពិសេសសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ដែលនឹងបញ្ចប់ក្នុងពេលខាងមុខនេះ និងការអនុញ្ញាតឱ្យបង្កើត និងដំណើរការស្ថាប័នព័ត៌មានទាំងជាតិនិងអន្តរជាតិនៅកម្ពុជា និងធ្វើការផ្សព្វផ្សាយដោយសេរី មិនមានការត្រួតពិនិត្យជាមុនឡើយ។ ប្រព័ន្ធផ្សព្វផ្សាយជាង២០០០ ដែលមានទាំងសំឡេងរិះគន់រដ្ឋាភិបាល បាន និងកំពុងដំណើរការដោយសេរី តាមរបៀបបែបប្រពៃណីនិងឌីជីថល ដោយគ្មានការត្រួតពិនិត្យជាមុនឡើយ។

សារព័ត៌មាន ជាវិជ្ជាជីវៈសេរី តែក៏ត្រូវស្ថិតក្រោមការគ្រប់គ្រងនិងក្របខណ្ឌច្បាប់ផងដែរ រួមមានច្បាប់ស្តីពីរបបសារព័ត៌មាននិងបញ្ញត្តិច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ មានន័យថា បើអ្នកសារព័ត៌មាន មានកំហុសខាងវិជ្ជាជីវៈ គឺត្រូវទទួលខុសត្រូវតាមច្បាប់ស្តីពីរបបសារព័ត៌មាន តែបើអ្នកសារព័ត៌មានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គឺត្រូវទទួលខុសត្រូវតាមបញ្ញត្តិច្បាប់ព្រហ្មទណ្ឌ។

វាជារឿងមិនត្រឹមត្រូវនិងសមហេតុសមផលនោះទេ ការដែលក្រុមមួយហៅខ្លួនឯងថាសារព័ត៌មានឯករាជ្យ ឬអ្នកវិភាគឯករាជ្យ ដោយសារតែខ្លួនហ៊ានរិះគន់រដ្ឋាភិបាលនោះ ព្រោះថាសារព័ត៌មាន និងអ្នកវិភាគវិជ្ជាជីវៈត្រូវធ្វើការផ្សព្វផ្សាយនិងវិភាគទាំងចំណុចវិជ្ជមាននិងអវិជ្ជមានរបស់រដ្ឋាភិបាល ដើម្បីជាប្រយោជន៍ដល់សង្គមនិងផ្តល់ព័ត៌មានពិតក៏ដូចជាចំណេះដឹងដល់សាធារណជន មិនមែនផ្តោតតែលើចំណុចអវិជ្ជមានដែលធ្វើឡើងដោយកំហឹង និងគុំនុំគុំគួនជាមួយរដ្ឋាភិបាលនិងដើម្បីបំរើផលប្រយោជន៍នយោបាយនោះទេ។

ការផ្សព្វផ្សាយព័ត៌មានឬការវិភាគដោយមិនផ្អែកលើវិជ្ជាជីវៈ និងមូលដ្ឋាននៃការស្រាវជ្រាវច្បាស់លាស់នឹងអាចប្រឈមនឹងការទទួលខុសត្រូវតាមផ្លូវច្បាប់ ប្រសិនបើការផ្សព្វផ្សាយព័ត៌មានឬការវិភាគនោះប៉ះពាល់និងរំលោភបំពានលើសិទ្ធិសេរីភាពនិងសេចក្តីថ្លៃថ្នូរអ្នកដ៏ទៃ និងបង្កចលាចលប៉ះពាល់ដល់សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ហើយការអនុវត្តច្បាប់លើអំពើល្មើសនេះ មិនមែនជាការគំរាមកំហែងដល់អ្នកសារព័ត៌មានឬអ្នកវិភាគឡើយ ហើយការផ្សាយនិងការវិភាគដែលបំពានច្បាប់ទាំងនេះក៏មិនមែនជាការអនុវត្តសិទ្ធិសេរីភាពសារព័ត៌មាននិងសិទ្ធិសេរីភាពនៃការសម្តែងមតិឬទស្សនៈតាមផ្លូវច្បាប់ នៅក្នុងសង្គមប្រជាធិបតេយ្យនោះដែរ។

ជាក់ស្តែងវិធានការរដ្ឋបាលក្នុងការបិទសារព័ត៌មាន VOD នាពេលថ្មីៗនេះ គឺដោយសារតែកំហុសវិជ្ជាជីវៈ ផ្សព្វផ្សាយព័ត៌មានមិនពិត ប៉ះពាល់ដល់សិទ្ធិសេរីភាពនិងសេចក្តីថ្លៃថ្នូរអ្នកដ៏ទៃ និងមានចរិតញុះញង់។ វិធានការនេះ មិនមែនជាការគំរាមកំហែងដល់សេរីភាពសារព័ត៌មានឡើយ តែផ្ទុយទៅវិញ វាជាវិធានការចាំបាច់ ក្នុងការលើកកម្ពស់ការអនុវត្តច្បាប់ និងសេរីភាពវិជ្ជាជីវអ្នកសារព័ត៌មាន។

**១០. សេរីភាពនៃការជួបជុំសម្តែងមតិ៖** ការជួបជុំតវ៉ាដោយសន្តិវិធី សហការជាមួយសមត្ថកិច្ច និងគោរពតាមវិធានការសន្តិសុខ សុវត្ថិភាព និងសុខភាពសាធារណៈ គឺជាការអនុវត្តសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ ប៉ុន្តែផ្ទុយទៅវិញ ការជួបជុំតវ៉ាដោយមិនបានជូនដំណឹងនិងសហការជាមួយសមត្ថកិច្ច បំពានវិធានការសន្តិសុខ សុវត្ថិភាព និងសុខភាពសាធារណៈ បង្កជាអំពើហិង្សានិងភាពចលាចលក្នុងសង្គម ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងសិទ្ធិសេរីភាពអ្នកដទៃ រួមទាំងការដាក់សម្ពាធដល់ស្ថាប័នតុលាការដែលជាស្ថាប័នឯករាជ្យផងដែរនោះ គឺជាអំពើល្មើសទៅនឹងច្បាប់ ដែលសមត្ថកិច្ចត្រូវចាត់គ្រប់វិធានការ ដើម្បីទប់ស្កាត់។ ចំណែកឯការបញ្ចេញមតិដោយបំផ្លើសនិងបំភ្លៃព័ត៌មានមិនពិត ក្នុងចេតនាទុច្ចរិត ញុះញង់ បង្កភាពចលាចល ប៉ះពាល់ដល់សន្តិសុខជាតិ មិនមែនជាការអនុវត្តសិទ្ធិនោះទេ ប៉ុន្តែជាបទល្មើសព្រហ្មទណ្ឌ ដែលអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ដែលមានជាធរមាន។

ដាក់ស្តែងវិធានការច្បាប់លើសកម្មជនសហជីប ***Naga World*** នាពេលថ្មីៗនេះ មិនមែនដោយសារតែការអនុវត្តនូវសិទ្ធសេរីភាពនៃការជួបជុំសម្តែងមតិ ឬសិទ្ធិសេរីភាពសហជីបនោះទេ តែដោយសារតែពួកគេបានបំពានវិធានការសន្តិសុខ សុវត្ថិភាព និងសុខភាពសាធារណៈ បង្កជាអំពើហិង្សានិងភាពចលាចលក្នុងសង្គម ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខជាតិ និងសិទ្ធិសេរីភាពអ្នកដទៃ ដែលជាអំពើល្មើសទៅនឹងច្បាប់ ហើយសមត្ថកិច្ចត្រូវចាត់គ្រប់វិធានការទប់ស្កាត់។ សកម្មភាពរបស់ពួកគេ មិនមែនជាការអនុវត្តសិទ្ធិនោះទេ តែជាបទល្មើសព្រហ្មទណ្ឌ ដែលអ្នកប្រព្រឹត្តត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ដែលមានជាធរមាន។

**១១. ការអនុវត្តច្បាប់លើសកម្មជននាពេលថ្មីៗនេះ** មិនមែនដោយសារតែពួកគេធ្វើសកម្មភាពការពារសិទ្ធិមនុស្ស បរិស្ថាន និងសង្គមនោះទេ ហើយក៏មិនមែនដោយសារតែពួកគេជាសកម្មជននោះដែរ តែផ្ទុយទៅវិញ គឺដោយសារតែពួកគេបានធ្វើសកម្មភាពល្មើសទៅនឹងច្បាប់ពាក់ព័ន្ធនឹងការជេរប្រមាថ ផ្សព្វផ្សាយព័ត៌មានមិនពិត ញុះញង់ អុចអាលក្នុងគោលដៅបង្កជាចលាចលដល់សន្តិសុខសង្គម ការប្រមាថអង្គព្រះមហាក្សត្រ និងរួមគំនិតក្បត់ជាដើម។ល។ ដែលសមត្ថកិច្ចមានភស្តុតាង និងមូលដ្ឋានច្បាស់លាស់ ក្នុងការចោទប្រកាន់និងដំណើការនីតិវិធីតាមផ្លូវតុលាការ។ ចំណែកឯការធ្វើយុទ្ធនាការរបស់សង្គមស៊ីវិល ក្នុងការការពារសកម្មជនល្មើសច្បាប់ទាំងនោះ គឺនឹងមិនមានឥទ្ធិពលអ្វីមកលើតុលាការ ដែលជាស្ថាប័នឯករាជ្យនោះទេ ព្រោះវាមិនមែនជាមធ្យោបាយតាមផ្លូវច្បាប់ក្នុងការការពារជនជាប់ចោទ តែផ្ទុយទៅវិញ មានតែការចូលរួមក្នុងដំណើរការនីតិវិធីរបស់តុលាការនោះទេ និងបង្ហាញសក្ខីកម្ម ភស្តុតាង ឱ្យបានរឹងមាំតាមផ្លូវច្បាប់ ដើម្បីដោះបន្ទុកនិងតតាំងជាមួយនឹងបទចោទរបស់សមត្ថកិច្ច ទើបជាមធ្យោបាយតាមផ្លូវច្បាប់តែមួយគត់ ក្នុងការការពារជនជាប់ចោទ ក្នុងសង្គមប្រជាធិបតេយ្យនីតិរដ្ឋ។

ការចាប់ខ្លួន ការចោទប្រកាន់ និងផ្តន្ទាទោសលើបុគ្គលខាងលើនោះ គឺធ្វើឡើងដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងសង្គមនីតិរដ្ឋ សិទ្ធិសេរីភាពបុគ្គលត្រូវយកមកអនុវត្តក្នុងក្របខណ្ឌច្បាប់ ហើយការអនុវត្តសិទ្ធិហួសព្រំដែនកំណត់របស់ច្បាប់ គឺប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ ហើយត្រូវប្រឈមនឹងការទទួលខុសត្រូវចំពោះមុខច្បាប់។ កម្ពុជាប្តេជ្ញាលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ដោយអនុលោមតាមច្បាប់របស់ខ្លួន ហើយដំណើរការប្រជាធិបតេយ្យ ក៏កំពុងប្រព្រឹត្តទៅជាទៀងទាត់ជាធម្មតា។ ម៉្យាងទៀត ប្រទេសនីមួយៗតែងមានអាទិភាពខុសៗគ្នា ដូចជាសហរដ្ឋអាមេរិក គឺ “ American First” ដោយឡែក សម្រាប់កម្ពុជា គឺ “Peace First”។ ផ្អែកលើប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្លួន ទិសស្លោក **“សូមអរគុណសន្តិភាព”** បានក្លាយជាទិសស្លោករបស់ប្រជាជនកម្ពុជា ក្នុងការបង្ហាញនូវបំណងប្រាថ្នារបស់ខ្លួន ដើម្បីរស់នៅដោយសេចក្តីសុខ ក្រោមម្លប់នៃសន្តិភាព។ ដូច្នេះ *“រាល់សកម្មភាពទាំងឡាយណា ដែលធ្វើឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញ ឬប៉ុនប៉ងបំផ្លិចបំផ្លាញដល់សុខសន្តិភាពនៅកម្ពុជា ពុំមែនជារឿងសិទ្ធិមនុស្ស ឬប្រជាធិបតេយ្យនោះឡើយ ប៉ុន្តែ វាគឺជារឿងខុសច្បាប់ ហើយជាការប្រឆាំងនឹងបំណងប្រាថ្នារួមរបស់ប្រជាពលរដ្ឋកម្ពុជា និងប្រឆាំងនឹងឧត្តមប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា”* ។

**១២. ភាពចង្អៀតណែនក្នុងពន្ធនាគារ៖** ការអំពាវនាវឱ្យដោះលែងអ្នកទោស របស់អង្គការសង្គមស៊ីវិលមួយចំនួន ដើម្បីដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារ ដោយមិនផ្អែកលើមូលដ្ឋាននិងនីតិវិធីច្បាប់ ដែលមានជាធរមាន មិនមែនជាវិធានការសមស្របនោះទេ តែផ្ទុយទៅវិញ វានឹងនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់សន្តិសុខនិងសណ្តាប់ធ្នាប់សង្គមទៅវិញទេ។

ភាពចង្អៀតណែនក្នុងពន្ធនាគារ ត្រូវតែដោះស្រាយដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ មានតែការដោះលែង ដោយផ្អែកតាមនីតិវិធីច្បាប់ជាធរមានទេ និងដែលបានអនុវត្តនាពេលបច្ចុប្បន្នមកផងដែរ ដូចជា វិធានការនៃការលើកលែងទោសនិងបន្ធូរបន្ថយទោស, ការដោះស្រាយភាពចង្អៀតណែនក្នុងពន្ធនាគារតាមរយៈការអនុវត្តយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងដែលដាក់ចេញដោយក្រសួងយុត្តិធម៌ និងការដោះលែងដោយមានលក្ខខណ្ឌ ក៏ដូចជាវិធានការដទៃទៀត ( *ការលើកលែងចោទប្រកាន់, ការសម្រេចដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន, ការសម្រេចឱ្យរួចផុតទោស, ការអនុវត្តទោសចប់របស់ទណ្ឌិត, ការព្យួរទោសធម្មតា, ការព្យួរទោសសាកល្បង, ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នក្នុងពន្ធនាគារ* ) ទើបអាចធានាបាននូវសន្តិសុខសង្គម និងកាត់បន្ថយការកើនឡើងជាគំហុកនៃចំនួនអ្នកជាប់ឃុំក្នុងពន្ធនាគារ។

**១៣. អំណាចតុលាការ និងការអនុវត្តច្បាប់៖** តុលាការ ជាស្ថាប័នឯករាជ្យ គ្មានជនណា ឬក្រុមអង្គការអន្តរជាតិណាមួយ អាចដាក់សម្ពាធ និងបង្គាប់បញ្ជាមកលើតុលាការបាននោះទេ។ ការចេញសេចក្តីថ្លែងការណ៍ ដាក់សម្ពាធនិងទាមទាឱ្យតុលាការ ដោះលែងជនជាប់ចោទនិងទម្លាក់ចោលបទចោទ មិនមែនជាមធ្យោបាយស្របច្បាប់ ក្នុងការការពារជនជាប់ចោទនោះទេ ហើយក៏នឹងមិនមានឥទ្ធិពលអ្វីដែរទៅលើការសម្រេចរបស់តុលាការដែលជាស្ថាប័នឯករាជ្យ។ ការកំណត់ពីពិរុទ្ធភាពបទល្មើស និងទោសទណ្ឌរបស់ជនល្មើស គឺជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការ ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុនិងអង្គច្បាប់ ដែលមានជាធរមាន គឺមិនមែនអាស្រ័យលើបក្សពួកឬក្រុមសម្ព័ន្ធមិត្តនិងអង្គការដែលគាំទ្រនិងការពារសកម្មភាពខុសច្បាប់របស់ជនល្មើសនោះទេ ហើយមធ្យោបាយតាមផ្លូវច្បាប់តែមួយគត់ក្នុងការការពារជនជាប់ចោទក្នុងសង្គមប្រជាធិបតេយ្យ នីតិរដ្ឋ គឺការចូលរួមក្នុងដំណើរនីតិវិធីតុលាការដើម្បីធ្វើការការពារខ្លួនតាមផ្លូវច្បាប់។

វិធានការច្បាប់របស់សមត្ថកិច្ចនាពេលកន្លងមក មិនបានផ្តោតដាក់លាក់ទៅលើក្រុមគោលដៅណាមួយនោះទេ ពោលគឺអនុវត្តជាទូទៅ មិនថាអ្នកទាំងនោះជាសកម្មជនសិទ្ធិមនុស្ស សង្គមស៊ីវិល នយោបាយ ឬបរិស្ថាននោះទេ ឱ្យតែប្រព្រឹត្តល្មើសទៅនឹងច្បាប់ ត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ដូចៗគ្នា ដោយមិនមានការលើកលែងឬអភ័យឯកសិទ្ធិពិសេសដោយឡែកណាមួយនោះទេ។ វិធានការច្បាប់ចំពោះក្រុមសកម្មជននាពេលថ្មីៗនេះ មិនមែនដោយសារតែពួកគេធ្វើសកម្មភាពក្នុងការការពារសិទ្ធិសេរីភាព បរិស្ថាន និងប្រយោជន៍សាធារណៈនោះទេ តែដោយសារតែពួកគេប្រព្រឹត្តបទល្មើស ដែលមានបញ្ញត្តិនៅក្នុងច្បាប់របស់កម្ពុជា ដោយមានអង្គការចាត់តាំងរៀបចំចាត់ចែងច្បាស់លាស់នៅពីក្រោយ ហើយដែលសមត្ថកិច្ចមានមូលដ្ឋានរឹងមាំក្នុងការចាត់វិធានការតាមផ្លូវច្បាប់និងដំណើរការនីតិវិធីតាមផ្លូវតុលាការ។

កម្ពុជា មិនមានអ្នកទោសនយោបាយនោះទេ មានតែអ្នកនយោបាយដែលមានទោស ដោយសារតែបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ ការអនុវត្តច្បាប់ចំពោះអ្នកនយោបាយដែលប្រព្រឹត្តបទល្មើស និងការរំលាយគណបក្សនយោបាយដែលប្រព្រឹត្តខុសច្បាប់ មិនមែនជាការរឹតត្បិតសិទ្ធិសេរីភាពផ្នែកនយោបាយ និងលំហប្រជាធិបតេយ្យ នោះទេ តែផ្ទុយទៅវិញជាវិធានការច្បាប់ដើម្បីលើកស្ទួយប្រជាធិបតេយ្យនិងនីតិរដ្ឋនៅកម្ពុជា។

**១៤. ស្ថានភាពសិទ្ធិមនុស្សក្រោយវិបត្តិជំងឺកូវីដ-១៩៖** ការប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩ ដ៏កាចសាហាវដែលបានឆ្លងរាតត្បាតយ៉ាងខ្លាំងក្នុងឆ្នាំ២០២០-២០២១ បានទទួលជោគជ័យ តាមរយៈការដឹកនាំដ៏ត្រឹមត្រូវ ការអនុវត្តវិធានការ និងយុទ្ធសាស្ត្រដ៏មុតស្រួចនានាប្រកបដោយប្រសិទ្ធភាព និងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋ ដែលបានពង្រឹងខឿនការពារសុខភាពរបស់ប្រជាជន ធានាដល់ដំណើការស្តារ និងជំរុញសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩។ វិស័យសេដ្ឋកិច្ចបានងើបឡើងវិញយ៉ាងឆាប់ ដោយសារការខិតខំប្រឹងប្រែងប្រកបដោយភាពបុរេសកម្ម និងភាពម្ចាស់ការរបស់រាជរដ្ឋាភិបាល តាមរយៈការដាក់ចេញវិធានការរក្សាលំនឹងសង្គម-សេដ្ឋកិច្ចទាន់ពេលជាបន្តបន្ទាប់។ លើមូលដ្ឋាននេះ សេដ្ឋកិច្ចកម្ពុជា ត្រូវបានរំពឹងថានឹងសម្រេច

បានកំណើនក្នុងរង្វង់ ៥,៥% ក្នុងឆ្នាំ២០២២ និងត្រូវបានព្យាករណ៍ថា នឹងសម្រេចបានកំណើន ៦,៦% នៅឆ្នាំ២០២៣។ ព្រមជាមួយនេះ ជីវភាពប្រជាជនរក្សាបានភាពនឹងន ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះដែលរងឥទ្ធិពលខ្លាំងពីវិបត្តិជំងឺកូវីដ-១៩ រួមទាំងប្រជាជនងាយរងហានិភ័យពីសម្ពាធនៃការឡើងថ្លៃទំនិញជាសាកល និងប្រជាជនរងគ្រោះដោយទឹកជំនន់ តាមរយៈការអនុវត្តកម្មវិធី និងវិធានការអន្តរាគមន៍សង្គមកិច្ចនានាបានទាន់ពេល។ នៅឆ្នាំ២០២៣នេះ មន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ត្រូវបានដំឡើងប្រាក់បៀវត្សមួយកម្រិតទៀត ព្រមជាមួយនេះ ប្រាក់សោធននិវត្តន៍របស់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនក៏ត្រូវបានកែសម្រួល និងដំឡើងផងដែរ, ដោយឡែកប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងសម្ភារៈធ្វើដំណើរ ក៏ត្រូវបានដំឡើងដល់ ២០០ដុល្លារ រួមទាំងការបន្តទទួលបានអត្ថប្រយោជន៍ផ្សេងៗ ពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ទាំងនេះបានបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការធានា និងការពារនូវសិទ្ធិរបស់ពលរដ្ឋ ទាំងក្នុងស្ថានភាពកូវីដ និងក្រោយវិបត្តិកូវីដ ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបាននូវសេវាសុខភាព សិទ្ធិទទួលបាននូវការអប់រំ និងសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌។

*ការវាយតម្លៃស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលលំអៀងនិងគ្មានមូលដ្ឋាន*

**១៥**. របាយការណ៍ចោទប្រកាន់ ដោយលំអៀងនិងគ្មានមូលដ្ឋានរបស់ក្រុមនិងអង្គការស្ថាប័នមួយចំនួន ដែលមាននិន្នាការនយោបាយប្រឆាំងនឹងរដ្ឋាភិបាល មិនបានឆ្លុះបញ្ចាំងពីការពិតជាក់ស្តែងនៅកម្ពុជានោះទេ ព្រោះថា របាយការណ៍ទាំងនេះ គ្រាន់តែធ្វើការប្រមូល បូកសរុបនូវព្រឹត្តិការណ៍ និងធ្វើការសន្និដ្ឋានតែលើរូបភាពខាងក្រៅតែប៉ុណ្ណោះ ពោលគឺមិនបានសិក្សាលើមូលហេតុលំអិតដែលនាំឱ្យកើតមានព្រឹត្តិការណ៍នីមួយៗ ទិដ្ឋភាពនិងនីតិវិធីច្បាប់ អង្គហេតុនៃបទល្មើស និងអំពើដែលជាធាតុផ្សំនៃបទល្មើស ដែលនាំឱ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់នោះទេ។

**១៦**. ជាទម្លាប់របស់អង្គការទាំងនេះ កាលណាអាជ្ញាធរអនុវត្តច្បាប់លើក្រុមគោលដៅដែលគេមានរបៀបវារៈច្បាស់លាស់ក្នុងការការពារ ដូចជាសកម្មជនអតីតបក្សប្រឆាំង សកម្មជនអង្គការសង្គមស៊ីវិលដែលមាននិន្នាការប្រឆាំង គឺពួកគេតែងតែធ្វើការសន្និដ្ឋាននិងចោទប្រកាន់ថាជាការរំលោភសិទ្ធិមនុស្ស ដោយមិនខ្វីអើពើនិងធ្វើការពិចារណារទៅទិដ្ឋភាពនិងនីតិវិធីច្បាប់ អង្គហេតុ អំពើដែលជាធាតុផ្សំនាំឱ្យកើតជាបទល្មើស ហើយដែលនាំឱ្យមានការទទួលខុសត្រូវតាមផ្លូវច្បាប់ និងការចោទប្រកាន់តាមផ្លូវតុលាការនោះទេ។

**១៧**.ការធ្វើរបាយការណ៍ដោយដកស្រង់យកតែទស្សនៈមួយជ្រុងនិងជួបសម្ភាសន៍ជាមួយមនុស្សមួយក្រុម និងអង្គការមួយចំនួនដែលជាបក្សពួករបស់ខ្លួន និងមាននិន្នាការប្រឆាំងនឹងរដ្ឋាភិបាលផងនោះ

ដោយមិនមានការចូលរួមនិងជាតុចូលពីតំណាងរដ្ឋាភិបាលនិងគ្រប់ភាគីពាក់ព័ន្ធដ៏ទៃទៀតដែលទទួលរងផលប៉ះពាល់អវិជ្ជមានពីរបាយការណ៍នេះ នោះការស្រាវជ្រាវ និងការសន្និដ្ឋានក្នុងរបាយការណ៍នេះមិនមានលក្ខណៈជាវិទ្យាសាស្ត្រ មិនមានភាពច្បាស់លាស់គ្រប់ជ្រុងជ្រោយ និងមិនអាចយកជាការបាននោះទេ។

១៨. ការចេញរបាយការណ៍មិនគ្រប់ជ្រុងជ្រោយ លំអៀង និងមានគោលដៅវាយប្រហាររដ្ឋាភិបាលបែបនេះ អាចនឹងនាំឱ្យមានគ្រោះថ្នាក់និងអស្ថិរភាពក្នុងសង្គម ព្រោះថារបាយការណ៍នេះហាក់ដូចជាការពារនិងលើកទឹកចិត្តដល់ក្រុមប្រឆាំងដែលតែងតែធ្វើសកម្មភាពក្រោមរូបភាពផ្សេងៗ ដែលរៀបចំ ឧបត្ថម្ភ និងគាំទ្រដោយចលនានិងអង្គការចាត់តាំងខុសច្បាប់នៅខាងក្រៅ ឱ្យកាន់តែធ្វើសកម្មភាពបន្ថែមទៀតដោយមិនខ្លាចច្បាប់ និងសមត្ថកិច្ច បង្កភាពចលាចលក្នុងសង្គម ដើម្បីសម្រេចឱ្យបាននូវមហិច្ឆតានយោបាយរបស់ខ្លួន ហើយដែលនេះមិនមែនជាការអនុវត្តនូវសិទ្ធិសេរីភាពតាមផ្លូវច្បាប់នោះទេ។ តែផ្ទុយទៅវិញ របាយការណ៍របស់អង្គការទាំងនេះ គួរតែធ្វើការអប់រំនិងណែនាំក្រុមដែលបំពានច្បាប់ទាំងនោះឱ្យគោរពច្បាប់ឱ្យបានខ្ជាប់ខ្ជួន ប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់ មិនបំពានសិទ្ធិសេរីភាពអ្នកដ៏ទៃ និងប៉ះពាល់ដល់សន្តិសុខសង្គមនិងសណ្តាប់ធ្នាប់សាធារណៈ ដែលអាចនាំឱ្យពួកគេប្រឈម និងទទួលខុសត្រូវតាមផ្លូវច្បាប់ជាយថាហេតុណាមួយ។

១៩.នៅក្នុងសង្គមប្រជាធិបតេយ្យនីតិរដ្ឋ ជាគោលការណ៍ សិទ្ធិមនុស្ស “Human Rights" ត្រូវតែគោរព និងការពារ តែបើមនុស្សប្រព្រឹត្តកំហុស “Human Wrong” ត្រូវតែប្រឈម និងទទួលខុសត្រូវតាមផ្លូវច្បាប់។

២០. ប្រជាធិបតេយ្យ មានគោលការណ៍រួម តែមិនមានស្តង់ដាររួមដែលតម្រូវឱ្យប្រទេសទាំងអស់ត្រូវតែអនុវត្តឱ្យបានដូចគ្នានោះទេ ពោលគឺ ការអនុវត្តត្រូវមានភាពបត់បែននិងប្រែប្រួលទៅតាមបរិបទនិងគុណតម្លៃនៃប្រទេសនិងតំបន់នីមួយៗ ដោយតម្កល់នូវប្រយោជន៍ជាតិខ្លួនជាធំ។ ដូច្នេះ ការវាយតម្លៃពីស្ថានភាពប្រជាធិបតេយ្យនិងសិទ្ធិមនុស្សក្នុងប្រទេសមួយដែលប្រកបដោយភាពសុក្រឹត្យ យុត្តិធម៌ ត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ មិនលំអៀងនោះ គឺត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍រួមផង ព្រមទាំងបរិបទ និងគុណតម្លៃនៃប្រទេសនិងតំបន់នោះផងដែរ និងមិនត្រូវវាយតម្លៃដោយផ្តោតតែទៅលើសិទ្ធិណាមួយ ហើយបំភ្លេចចោលនូវវឌ្ឍនភាពនៃការអនុវត្តសិទ្ធិដ៏ទៃទៀតនោះទេ។

២១. វាបានបង្ហាញឱ្យឃើញច្បាស់ ពីការបាត់បង់សណ្តាប់ធ្នាប់អន្តរជាតិ និងភាពអនាធិបតេយ្យនៃនយោបាយអន្តរជាតិ នាពេលថ្មីៗនេះ ការដែលរដ្ឋមួយអាចរៀបចំច្បាប់តាមទំនើងចិត្តនិងជាឯកតោភាគី លូកលាន់ចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដ៏ទៃក្រោមលេសប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស ព្រមទាំងដាក់ទណ្ឌកម្ម

លើរដ្ឋ ថ្នាក់ដឹកនាំ និងសហគ្រាសឯកជន នៃរដ្ឋអធិបតេយ្យមួយទៀត ដោយមិនឆ្លងកាត់យន្តការរបស់អង្គការសហប្រជាជាតិ ហើយដែលទង្វើនេះធ្វើឡើងក្រោមរូបភាព និងផលប្រយោជន៍នយោបាយ ជាជាងហេតុផលសិទ្ធិមនុស្ស។

**២២**. ទោះបីជាដឹងយ៉ាងច្បាស់ថា វិធានការរបស់ប្រទេស និងស្ថាប័នអន្តរជាតិមួយចំនួន មកលើកម្ពុជា មានភាពលំអៀង អយុត្តិធម៌ មានស្តង់ដារពីរ ដែលធ្វើឡើងក្រោមហេតុផលនយោបាយ និងយកប្រជាធិតេយ្យនិងសិទ្ធិមនុស្សធ្វើជាលេស ដើម្បីជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា យ៉ាងណាក៏ដោយក៏កម្ពុជានៅតែបន្តកិច្ចសហប្រតិបត្តិការជាមួយគ្រប់យន្តការអន្តជាតិនិងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដោយប្រកាន់ភ្ជាប់នូវគោលនយោបាយការបរទេស សន្តិសហវិជ្ជមាន ឯករាជ្យផ្អែកលើច្បាប់ មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋដ៏ទៃ ព្រមទាំងការពារនិងថែរក្សាឱ្យបាននូវសន្តិភាព អធិបតេយ្យភាព ឯករាជ្យភាព និងតម្កល់នូវប្រយោជន៍ជាតិជាធំ តាមរយៈយន្តការនៃការអនុវត្តច្បាប់យ៉ាងម៉ឺងម៉ាត់និងគ្មានការលើកលែងផ្អែកតាមគោលការណ៍និងបែបបទប្រជាធិបតេយ្យនីតិរដ្ឋ។

សម្រាប់ព័ត៌មានលំអិតបន្ថែម សូមទាក់ទង ឯកឧត្តម **ជិន ម៉ាលីន** អនុប្រធាននិងជាអ្នកនាំពាក្យគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា តាមរយៈទូរសព្ទ័លេខ ០៦១ ៦៦៦ ៧៧៨ ។

ថ្ងៃពុធ ៨កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣

**គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**